គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

ថ្ងៃទី០២ ខែមិនា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតនៅឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ

ដោយមានការគាំទ្រពី គណៈកម្មាធិការខុមហ្វ្រែល សហការជាមួយនឹង **សមាគមអាដហុក** បានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតមួយ ស្តីពី **ការកំណត់តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ដាច់ស្រយាល** ដែលធ្វើឡើងនៅ**ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ** កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២។ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ **៩៨**នាក់ **(៣៧%**ជាស្ត្រី) ពីគ្រប់ភូមិក្នុងឃុំ ដែលរួមមាន តំណាងសហគមន៍ តំណាងគណបក្សនយោបាយប្រចាំឃុំ សមាជិកក្រុមប្រឹក្សាឃុំ អាជ្ញាធរភូមិ អង្គការមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងឃុំបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ។

ប្រជាពលរដ្ឋដែលចូលរួមសិក្ខាសាលាស្ទើរតែ ១០០% បានបោះឆ្នោតគាំទ្រតម្រូវការជាអាទិភាពទាំង៥ នៅក្នុងឃុំ ដែលស្នើឱ្យក្រុមប្រឹក្សាឃុំបច្ចុប្បន្នយកចិត្តទុកដាក់ដោះស្រាយ និង/ឬ គណបក្សនយោបាយទទួលយកដើម្បីដាក់បញ្ចូលទៅក្នុង កម្មវិធីនយោបាយរបស់ខ្លួនក្នុងការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ។

### តម្រូវការជាអាទិភាពទាំង ៥ ក្នុងឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ

**១. ស្ពាន និងជួសជុលទំនប់ទឹក**

- សុំស្ពារ និងជួសជុលទំនប់ទឹកចំនួន២កន្លែង គឺ**ទី១**នៅភូមិស្រែត្រែងចំណុចភ្នំស្រួច ដោយធ្វើការស្ពារជម្រៅ២ម៉ែត្រ និងជួសជុលប្រវែង១៣ម៉ែត្រ **ទី២**ស្ពារ និងជួសជុលទំនប់ទឹកនៅភូមិអូរតាណឹង ដែលមានប្រវែងសរុប៧០ម៉ែត្រ។ សូមឲ្យបាននៅឆ្នាំ២០១២នេះ។

**២. ការសាងសង់ផ្លូវ និងស្ពាន**

- ស្នើសុំផ្លូវ២ខ្សែ និងស្ពាន១កន្លែងនៅ**ភូមិចង្ហប**គឺ៖ **ខ្សែទី១**ពីចំណុចផ្លូវជាតិទល់អូររាំង មានប្រវែង១០០០ម៉ែត្រ និងទទឹង៧ម៉ែត្រ ជាប្រភេទផ្លូវក្រាលគ្រួសក្រហម និងមានធ្វើស្ពាន១កន្លែងធ្វើអំពីដែក មានទទឹង៨ម៉ែត្រ បណ្តោយ៣០ម៉ែត្រ ដោយប្រើលូ២កន្លែង ក្នុង១កន្លែងប្រើលូ៩កង់ មានមុខកាត់៨តឹក ហើយលូទី១ដាក់ត្រង់ចំណុចផ្លូវបំបែកក្នុងភូមិ និងលូទី២ដាក់ត្រង់ចំណុចផ្លូវត្រពាំងសង្កែ។ **ខ្សែទី២**ពីចំណុចម៉ាត់អូររាំង មកទល់សាលារៀនចង្ហប មានប្រវែង១៥០០ម៉ែត្រ ទទឹង៧ម៉ែត្រ ជាប្រភេទផ្លូវក្រាលគ្រួសក្រហម និងមានប្រើលូ២កន្លែង ដោយ១កន្លែងៗប្រើលូ៩កង់ មានមុខកាត់៨តឹក ហើយលូទី១ដាក់នៅចំណុចខាងជើងស្រះចង្ហប លូទី២ដាក់នៅចំណុចផ្ទះស្វាយ ហឿន។ សូមចាប់ផ្តើមឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office** : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

- ស្នើសុំជួសជុសផ្លូវលំ១ខ្សែ និងធ្វើផ្លូវថ្មី១ខ្សែនៅ**ភូមិអូតាណឹង** ជាប្រភេទផ្លូវក្រាលគ្រួសក្រហមគឺះ

  -**ជួសជុសផ្លូវ**លំ១ខ្សែ មានប្រវែង១៥០០ម៉ែត្រ ទទឹង៧ម៉ែត្រ ពីចំណុចមុខប៉ុស្ដិ៍សុខភាព មកទល់ខាងលិចភូមិ ដោយមានប្រើលូ៤កន្លែង **លូទី១**នៅចំណុចប៉ុស្ដិ៍សុខភាព ប្រើលូ៦កង់ មានមុខកាត់៨តឹក **លូទី២**ចំណុចស្រះទឹកស្អាតសហាគមន៍ប្រើលូ៤កង់ មានមុខកាត់៧តឹក **លូទី៣**ចំណុចពាក់កណ្ដាលផ្លូវប្រឡាយត្រពាំងព្រៃ ប្រើលូ៤កង់ មានមុខកាត់៧តឹក **លូទី៤**ចំណុចផ្លូវលំ ប្រើលូ៤កង់ មានមុខកាត់៧តឹក

  -**សាងសង់ផ្លូវ**ថ្មី១ខ្សែ ពីចំណុចផ្លូវលំចាស់ ទល់ផ្លូវតាសូត្រ មានប្រវែង១៥០០ម៉ែត្រ ទទឹង៧ម៉ែត្រ។ សូមចាប់ផ្ដើមឆ្នាំ២០១២ បញ្ចប់ឆ្នាំ២០១៣។
- សុំធ្វើផ្លូវលំ២ខ្សែជាប្រភេទផ្លូវក្រាលគ្រួសក្រហមនៅ**ភូមិអូរពោរ៍**គឺះ **ខ្សែទី១** មានប្រវែង៦០០០ម៉ែត្រ ទទឹង៧ម៉ែត្រ ពីចំណុចផ្លូវជាតិ ទល់អូរពោរ៍លិច ដោយមានធ្វើ**ស្ពាន**១កន្លែង ប្រវែង១០ម៉ែត្រ ទទឹង៥ម៉ែត្រ ជាប្រភេទស្ពានដែក នៅចំណុចអូរពោរ៍ និងប្រើលូ១កន្លែងចំនួន៨កង់ មានមុខកាត់៨តឹក នៅចំណុចប្រឡាយស្រែកំព្រិច។ **ខ្សែទី២** មានប្រវែង៣០០០ម៉ែត្រ ទទឹង៧ម៉ែត្រ ពីចំណុចផ្លូវជាតិ ទល់ប្រឡាយស្រែកំព្រិច ដោយប្រើលូ១កន្លែងចំនួន៤កង់ មានមុខកាត់៨តឹក។ សូមចាប់ផ្ដើមឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។
- ស្នើសុំផ្លូវ១ខ្សែនៅ**ភូមិស្រែស្បូវ** មានប្រវែង៣០០០ម៉ែត្រ ទទឹង៧ម៉ែត្រ ជាប្រភេទផ្លូវក្រាលគ្រួសក្រហមដោយមានប្រើលូចំនួន៣កន្លែងគឺះ **លូទី១**ចំណុចត្រពាំងត្នោត ដាក់លូ៣កង់ មានមុខកាត់៨តឹក **លូទី២**ចំណុចដីប្រឡាយទេបខុន ដាក់លូ៣កង់ មានមុខកាត់៨តឹក **លូទី៣** ចំណុចត្រពាំងខ្យង ដាក់លូ៣កង់ មានមុខកាត់៨តឹក។ សូមចាប់ផ្ដើមឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។

**៣. ការស្នើសុំអណ្ដូងទឹក**

- សុំអណ្ដូងទឹកចំនួន៥អណ្ដូង ជាប្រភេទអណ្ដូងស្នប់នៅ**ភូមិស្រែស្បូវ** ដោយដាក់នៅចំណុចកណ្ដាលភូមិ១អណ្ដូង ចំណុចចុងភូមិ១អណ្ដូង ចំណុចកណ្ដាលភូមិ១អណ្ដូង ចំណុចត្រពាំងល្អក់១អណ្ដូង និងចំណុចកាតេ ១អណ្ដូង។
- សុំអណ្ដូងទឹកចំនួន៣អណ្ដូង ជាប្រភេទអណ្ដូងស្នប់នៅ**ភូមិអូរពោរ៍** ដោយដាក់នៅចំណុចសាលាបុណ្យ១អណ្ដូង ចំណុចកណ្ដាលភូមិ១អណ្ដូង ចំណុចចុងភូមិ១អណ្ដូង។
- សុំអណ្ដូងទឹកចំនួន៥ ជាប្រភេទអណ្ដូងស្នប់នៅ**ភូមិអូរតាណឹង** ដោយដាក់នៅចំណុចខាងលើសាលារៀនអូរតាណឹង១អណ្ដូង ចំណុចខាងលើប៉ុស្ដិ៍សុខភាព១អណ្ដូង ចំណុចពាក់កណ្ដាលភូមិផ្លូវលំ១អណ្ដូង ចំនុចប្រឡាយទឹកត្រពាំងព្រៃ១អណ្ដូង និងចំណុចទួលតាសូត្រ១អណ្ដូង។
- សុំអណ្ដូងទឹកចំនួន៥អណ្ដូងនៅ**ភូមិស្រែត្រែង** ដោយប្រភេទអណ្ដូងស្នប់សូមដាក់នៅចំណុចផ្លូវខាងកើត

ផ្លូវភ្នំស្រួច១អណ្តូង ចំណុចខាងលិចផ្លូវភ្នំស្រួច១អណ្តូង និងជាប្រភេទអណ្តូងតៅសូមដាក់នៅចំណុចផ្លូវតុងមិន១អណ្តូង ចំណុចអូរអន្ទង់១អណ្តូង និងចំណុចស្រែឈ្លិច១អណ្តូង។

- សុំអណ្តូងចំនួន៤នៅ**ភូមិចង្ហប** ជាប្រភេទអណ្តូងជាប្រភេទអណ្តូងស្នប់ ដោយដាក់នៅចំណុចក្បាលភូមិ១អណ្តូង ចំណុចស្រះខាងត្បូង១អណ្តូង ចំណុចដីភោគសាន១អណ្តូង និងចំណុចដីន-ផល្លា១អណ្តូង។ រាល់សំណើទាំងអស់ខាងលើនេះសូមចាប់ផ្តើមឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។

**៤. ការសាងសង់សាលារៀន**

- សុំសាលារៀនបឋមសិក្សា១ខ្នងនៅ**ភូមិអូរពោរ៍** មាន៤បន្ទប់ ធ្វើអំពីថ្ម និងគ្រូបង្រៀនចំនួន៣នាក់ រួមមានទាំងសំភារៈឧបទ្ទេសដូចជា តុ កៅអី ក្តារខៀន។
- សុំកសាងរបង និងក្លោងទ្វារសាលាបឋមសិក្សា និងអនុវិទ្យាល័យក្បាលដំរីនៅ**ភូមិអូរតាណឹង** ជាប្រភេទរបងថ្ម មានប្រវែង២១០០ម៉ែត្រ។
- សុំកសាងរបងសាលាបឋមសិក្សាស្រែត្រែងនៅ**ភូមិស្រែត្រែង** មានប្រវែង៦០០ម៉ែត្រ ជាប្រភេទរបងថ្ម និងចាក់ដីក្នុងទីធ្លាឲ្យខ្ពស់ដើម្បីការពារទឹកលិចពេលរដូវវស្សា។
- សុំសាលាបឋមសិក្សា១ខ្នង មាន៤បន្ទប់នៅ**ភូមិស្រែស្បូវ** និងគ្រូបង្រៀន២នាក់ សំភារៈឧបទ្ទេសរួមមាន តុ កៅអី ក្តារខៀន សំភារៈសិក្សាផ្សេងៗ និងសុំចាក់ដីក្នុងទីធ្លាសាលាបន្ថែមទៀតឲ្យខ្ពស់ដើម្បីការពារទឹកលិចពេលរដូវវស្សា។
- សុំសាងសង់សាលាបឋមសិក្សាចង្ហបនៅ**ភូមិចង្ហប** មានប្រវែង១២០ម៉ែត្រx១០០ម៉ែត្រ ជាប្រភេទរបងថ្ម។ រាល់សំណើរទាំងអស់ខាងលើនេះសូមកសាងឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។

**៥. ការស្នើសុំដីលំនៅដ្ឋាន និងដីកសិកម្ម**

- អ្នកភូមិស្រែស្បូវចំនួន**១៦០គ្រួសារ** ភូមិអូរពោរ៍ចំនួន**៣៥គ្រួសារ** ភូមិចង្ហបចំនួន**៦២គ្រួសារ** បានស្នើសុំដីលំនៅដ្ឋាន និងដីកសិកម្ម ហើយភូមិអូរតាណឹងចំនួន**៨៥គ្រួសារ** ភូមិស្រែត្រែងចំនួន**៥៦គ្រួសារ**បានស្នើសុំដីសម្រាប់ធ្វើកសិកម្ម។ សំណើរនេះសូមឲ្យបាននៅឆ្នាំ២០១២នេះ។

មុនពេលបញ្ចប់សិក្ខាសាលាមានកម្មវិធីប្រគល់របាយការណ៍ពីតម្រូវការជាអាទិភាពដល់អ្នកដឹកនាំគណបក្សនយោបាយប្រចាំឃុំ និងក្រុមប្រឹក្សាឃុំ។

លោក **ស្រែ ទុន** តំណាងគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមប្រឹក្សាឃុំ មានប្រសាសន៍ថា ៉លោកបានធ្វើការគ្រាំទ្រទៅលើតម្រូវការជាអាទិភាពទាំង៥ដែលអង្គសិក្ខាសាលាបានឡើងឡើងនៅថ្ងៃនេះ។ លោកបញ្ជាក់ថា តម្រូវការទាំងនះសុទ្ធសឹងតែមានដាក់បញ្ចូលទៅក្នុងផែនការឃុំឆ្នាំ២០១២-២០១៣ ជា

ពិសេសតម្រូវការទំនប់នៅស្រែត្រែងគឺ ឃុំបានដាក់ទៅក្នុងផែនការសមាហរណកម្មរួចហើយ រង់ចាំតែការដេញថ្លៃពីក្រុមហ៊ុនតែប៉ុណ្ណោះ។ ហើយបញ្ហាដីកសិកម្ម ឃុំបានដាក់សុំណើទៅថ្នាក់ជាតិរួចហើយផងដែរ។ លោកក៏បានបន្តទៀតថាទោះបីមានតម្រូវការ ឃុំអាចអនុវត្តបានសំរាប់អាណត្តិនេះតែលោក នឹងទទួលយកទៅអនុវត្តនៅអាណត្តិក្រោយទៀត ប្រសិនបើប្រជាពលរដ្ឋនៅតែគ្រាំទ្រលើការដឹកនាំរបស់លោក"។

លោក **អ៊ុច ចាន់តូ** តំណាងគណបក្សសមរង្ស៊ី និងជាជំទប់ទី១ឃុំក្បាលដំរី បានចូលរួមលើកឡើងថា "លោកសុំឯកភាពតាមយោបល់របស់លោកមេឃុំចំពោះការដាក់បញ្ចូលផែនការឃុំនូវរាល់តម្រូវការជាអាទិភាពទាំង៥នេះ។ ប៉ុន្តែលោកបានបញ្ជាក់ថាឃុំ នឹងអនុវត្តបានទៅលើគម្រោង ឬតម្រូវការទាំងឡាយដែលមិនប៉ះពាល់អំណាចថ្នាក់កណ្តាល ដោយចំណាយថវិកាតិច។ ចំពោះតម្រូវការដីធ្លី វាជាសមត្ថកិច្ចរបស់អាជ្ញាធរថ្នាក់ជាតិ"។

លោក **សៅ ទូន** ជំទប់ទី២ឃុំក្បាលដំរី និងជាតំណាងគណៈបក្សនរោត្តមរណឫទ្ធិ បានលើកឡើងថា "ការងារដែលបានគ្រប់គ្រងក្នុងអាណត្តិ និងការគ្រប់គ្រងសុវត្ថិភាពមូលដ្ឋាន គឺធ្វើយ៉ាងណាលុបបំបាត់ឲ្យបានតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។ តែសំរាប់ឃុំក្បាលដំរីពាក់ព័ន្ធវិវាទដីធ្លី ក្មេងទំនើង ការវាយបង្ករបួសស្នាម នៅកើតមានជាហូរហែរនៅមិនទាន់លប់បំបាត់នៅឡើយ។"

**សិក្ខាសាលានេះមានគោលបំណងឲ្យម្ចាស់ឆ្នោតនៅតំបន់ដាច់ស្រយាលទទួលបាន៖**

១. ការយល់ដឹងអំពីសិទ្ធិតួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោតក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍នូវមូលដ្ឋាន។

២. ផ្តល់ឱកាសឱ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ-សង្កាត់របស់ខ្លួន។

៣. តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ ដាច់ស្រយាលនឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដានជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០១២។

សិក្ខាសាលានេះក៏បានទទួលការឧបត្ថម្ភមូលនិធិពីសហភាពអឺរុប (EU), OXFAM NOVIB, NPA និង Forum Syd

**[1]សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

១-លោក **ម្លូខ មឿត** (មន្ត្រីផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១២ ៤៧១ ៣២៦**

---

[1] No. 086

២-លោកស្រី **ហេង សុគន្ធា** (ជំនួយការផ្នែកបណ្តាញ និងវេទិកា)
ទូរស័ព្ទលេខ ៖ **០១៧ ៥៨៣ ៨៦៩**

**<u>បេសកម្ម</u>** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌**តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។